**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

លេខៈ ២៧១ ហាគ.កបទ.សអ

# សេចក្ដីជូនដំណឹង
# ស្ដីពីការដេញថ្លៃការផ្គត់ផ្គង់ប្រេងឥន្ធនៈ ឆមាសទី១ ឆ្នាំ២០២៣

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សូមជូនដំណឹងដល់បណ្ដាក្រុមហ៊ុន ឬសហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជា ជ្រាបថា ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នឹងដាក់ឲ្យដេញថ្លៃជាសាធារណៈនូវការផ្គត់ផ្គង់ប្រេងឥន្ធនៈ ឆមាសទី១ ឆ្នាំ២០២៣ ដូចមានព័ត៌មានខាងក្រោមៈ

-ឯកសារសម្រាប់ការចូលរួមដេញថ្លៃមានផ្ដល់ជូន នៅអង្គភាពលទ្ធកម្មទីស្ដីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អាសយដ្ឋានលេខ៣ វិថីសម្ដេចហ៊ុនសែន សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៣ រហូតដល់ថ្ងៃឈប់ទទួលពាក្យនៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោង ០៩:០០ នាទីព្រឹកជាកំហិត

-ការបើកឯកសារដេញថ្លៃជាផ្លូវការ នឹងប្រព្រឹត្តទៅនៅវេលាម៉ោង ០៩:០០នាទីព្រឹក នាថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៣ នៅអាសយដ្ឋានខាងលើដដែល

-ក្រុមហ៊ុន ឬសហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងអង្គភាពលទ្ធកម្ម នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ តាមអាសយដ្ឋានខាងលើនេះរៀងរាល់ម៉ោងធ្វើការ។

ថ្ងៃសុក្រ ៤រោច ខែ មាឃ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ ២០២៣

**ជ.ប្រធានគណៈកម្មាធិការលទ្ធកម្ម**
**អនុប្រធាន**

**ញឹម ខេមរា**

**ចម្លងជូនៈ**
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
(អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ)
-ឯកសារ កាលប្បវត្តិ

អាសយដ្ឋានៈ លេខ ៣ វិថី សម្ដេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល: mfaic@mfaic.gov.kh